អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ
លេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៣)
ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០៧

## នីតិវិធីជំនុំជម្រះរឿងព្រហ្មទណ្ឌ
## (ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ ម៉ោង ៩ៈ០០ ព្រឹក)
## សវនាការសាធារណៈ

**ការកំណត់ពេលវេលា**
**វគ្គទី១ៈ** ម៉ោង៩ៈ០០-១០ៈ១៥
១៥ នាទី សំរាប់សំរាក
**វគ្គទី២ៈ** ម៉ោង១០ៈ៣០-១១ៈ៤៥
សំរាកសំរាប់អាហារថ្ងៃត្រង់
**វគ្គទី៣ៈ** ម៉ោង១២ៈ៤៥-២ៈ០០
១៥ នាទី សំរាប់សំរាក
**វគ្គទី៤** (បន្ទាប់ពីស្តាប់ភាគី)ៈ ម៉ោង២ៈ១៥-៣ៈ៣០

### ៨ៈ៤៥ នាទីព្រឹក

- សាធារណៈជនមានវត្តមានក្នុងសាលសវនាការ
- សហមេធាវី និងជនត្រូវចោទមានវត្តមានក្នុងសាលសវនាការ
- សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមានក្នុងសាលសវនាការ
- ក្រឡាបញ្ជីជាតិប្រកាសបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្ងៃសវនាការ
- កណ្តឹងលើកទី១ៈ សហព្រះរាជអាជ្ញាចូលកាន់សាលសវនាការ

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

# ៩:០០ នាទីព្រឹក

-កណ្តឹងលើកទី២: ក្រឡាបញ្ជីអញ្ជើញភ្ញៀវទាំងអស់អោយក្រោកឈរ ដោយស្រែកថា "តុលាការ" ក្រុមប្រឹក្សាជំនុំជម្រះចូលក្នុងសាលសវនាការ

-ប្រធានបង្គាប់អោយអង្គុយចុះ។

## ប្រធានប្រកាស

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសបើកសវនាការ ដើម្បីជំនុំជម្រះរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៣) ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលមាន ៖

- ជនត្រូវចោទឈ្មោះ **អៀង សារី** ហៅ **វ៉ាន់** សញ្ជាតិខ្មែរ ភេទ ប្រុស កើតនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩២៥ នៅភូមិលឿង វ៉ា ឃុំលឿង វ៉ា ស្រុកត្រាវិញ ខេត្តត្រាវិញ កម្ពុជាក្រោម ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ ៤៧បេ ផ្លូវលេខ២១ ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេស កម្ពុជា ឪពុកឈ្មោះ **គីម រៀម** (ស្លាប់) ម្តាយឈ្មោះ **ត្រាន់ ធិឡឺយ** (ស្លាប់) ប្រពន្ធឈ្មោះ **អៀង ធីរិទ្ធ** មានកូនចំនួន ៤នាក់ ។

- ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ដែលត្រូវផ្តន្ទាទោសតាម មាត្រា៥, មាត្រា៦, មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ ។

- មានមេធាវីការពារ: លោក **អាង ឧត្តម**
លោក Michael KARNAVAS

- មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោក គង់ ពិសី

លោកស្រី Silke STUDZINSKY

## ប្រធានស្នងក្រឡាបញ្ជី

តើអ្នកចូលរួមសវនាការមានវត្តមានគ្រប់ចំនួនហើយឬនៅ ?

## ប្រធានប្រកាស

ការជំនុំជម្រះថ្ងៃនេះ មានសមាសភាពដូចតទៅ:

| | |
|---|---|
| ១. លោក **ធ្នាក់ គឹមសាន** | **ប្រធាន** |
| ២. លោក Rowan DOWNING | ចៅក្រម |
| ៣. លោក **ន័យ ថុល** | ចៅក្រម |
| ៤. លោកស្រី KatinKa LAHUIS | ចៅក្រម |
| ៥. លោក **ហួត វុទ្ធី** | ចៅក្រម |
| • លោក **ម៉ែន ពេជ្ជសាលី** | ចៅក្រមបំរុង |

- ក្រឡាបញ្ជី: លោក **កែវ វ៉ាន្នី**

លោក Dirk Jan LAMAN

- សហព្រះរាជអាជ្ញា: លោក **យ៉េត ចរិយា**

លោក **William Smith**

## <u>ប្រធានអញ្ជើញជនត្រូវចោទមកឈរមុខចៅក្រម</u>

*<u>*ជនត្រូវចោទនាំមកកាន់មុខក្រេចកសេះ*</u>

លោកឈ្មោះអ្វី ? មានឈ្មោះហៅក្រៅទេ ? អាយុប៉ុន្មាន ? សញ្ជាតិអ្វី ? កើតនៅភូមិណា ? សង្កាត់ណា ? ស្រុកណា ? ខេត្តណា ? មុខរបរ ? ទីលំនៅ មុនពេលចាប់ខ្លួន ? ឪពុកឈ្មោះអ្វី ? ម្តាយឈ្មោះអ្វី ? ប្រពន្ធឈ្មោះអ្វី ? មានកូនប៉ុន្មាននាក់ ? តើមានពឹងអ្នកការពារ ឬ មេធាវីដែរឬទេ ? ហើយមានឈ្មោះ?

## <u>ប្រធានប្រាប់សិទ្ធិដល់ជនជាប់ចោទ (វិធាន ២១-១ (ឃ))</u>

*អនុលោមតាមវិធាន២១-១ (ឃ) នៃវិធានផ្ទៃក្នុង ជនត្រូវចោទ **អៀង សារី**ៈ*

*- លោកត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់លោក មិនទាន់ត្រូវបាន រកឃើញ*

*- លោកមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន*

*- លោកមានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន និង*

*- លោកមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។*

## <u>ប្រធានអញ្ជើញចៅក្រមរបាយការណ៍អានរបាយការណ៍</u>

- ចៅក្រម **ន័យ ថុល** (ចៅក្រមជាតិ) អានរបាយការណ៍សង្ខេប

## <u>ប្រធានអញ្ជើញជនត្រូវចោទក្រោកឈរ</u>

ប្រធានសួរជនត្រូវចោទ ថាតើលោកចង់និយាយទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ដោយខ្លួនឯង រឺក៏ចង់អោយសហមេធាវីរបស់លោកនិយាយក្នុងនាមអោយលោក។

*<u>*ជនត្រូវចោទត្រូវបានអញ្ជើញត្រលប់ទៅកាន់កន្លែងអង្គុយជាប់នឹងមេធាវីការពារក្តីវិញ បញ្ហាបឋមនានាដែលលើកឡើងដោយភាគីនឹងត្រូវបានស្តាប់</u>*

**I-ប្រធានអញ្ជើញសហមេធាវីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបទាក់ទងនឹងបញ្ហា**

**យុត្តាធិការ (បញ្ហាបឋម និងការកាត់ទោសពីរដង)**

វិធាន ២២-២(ក)ៈ មេធាវីជាតិត្រូវស្នើអោយទទួលស្គាល់មេធាវីអន្តរជាតិ នៅពេលដែលមេធាវីអន្តរជាតិនោះបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខអង្គភាពតុលាការនីមួយៗរបស់អង្គជំនុំជម្រះវិសាមញ្ញ

( រយៈពេល ១ ម៉ោង ៣០ នាទី សម្រាប់សហមេធាវីតាមពេលសមស្រប)

**ប្រធានអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប**

( រយៈពេល ១ ម៉ោង ៣០ នាទី សម្រាប់សហព្រះរាជអាជ្ញាតាមពេលសមស្រប)

**ប្រធានអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប**

( រយៈពេល ១ ម៉ោង ៣០ នាទី សម្រាប់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតាមពេលសមស្រប)

**ប្រធានអនុញ្ញាតអោយធ្វើការឆ្លើយតបទៅវិញទៅមក**

**ចៅក្រមអាចសួរសំណួរ**

**II-ប្រធានអញ្ជើញសហមេធាវីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបទាក់ទងនឹងបញ្ហា**

**យុត្តាធិការ (ការលើកលែងទោស/ការអនុគ្រោះទោស)**

( រយៈពេល ១ ម៉ោង សម្រាប់សហមេធាវីតាមពេលសមស្រប)

**ប្រធានអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប**

( រយៈពេល ១ ម៉ោង សម្រាប់សហព្រះរាជអាជ្ញាតាមពេលសមស្រប)

**ប្រធានអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប**

( រយៈពេល ១ ម៉ោង សម្រាប់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតាមពេលសមស្រប)

**ប្រធានអនុញ្ញាតអោយធ្វើការឆ្លើយតបទៅវិញទៅមក**

**ចៅក្រមអាចសួរសំណួរ**

**III-<u>ប្រធានអញ្ជើញសហមេធាវីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបទាក់ទងនឹងបញ្ហាការឃុំខ្លួនបណ្តោះអាសន្ន</u>**

( រយៈពេល ១ ម៉ោង ៣០ នាទី សម្រាប់សហមេធាវីតាមពេលសមស្រប)

**<u>ប្រធានអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប</u>**

( រយៈពេល ១ ម៉ោង ៣០ នាទី សម្រាប់សហព្រះរាជអាជ្ញាតាមពេលសមស្រប)

**<u>ប្រធានអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប</u>**

( រយៈពេល ១ ម៉ោង សម្រាប់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតាមពេលសមស្រប)

**<u>ប្រធានអនុញ្ញាតអោយធ្វើការឆ្លើយតបទៅវិញទៅមក</u>**

**<u>ចៅក្រមអាចសួរសំណួរ</u>**

**<u>ប្រធានសួរជនត្រូវចោទថាតើមានអ្វីចង់បន្ថែមដែរឬទេ</u>**

**<u>ប្រធានជូនព័ត៌មានទាក់ទងអំពីការប្រកាសសាលដីកា</u>**

**<u>ប្រធានបញ្ជាប់ឲ្យក្រុមការពារនាំជនត្រូវចោទត្រឡប់ទៅមន្ទីរឃុំឃាំងវិញ</u>**

**<u>ប្រធានប្រកាសបិទសវនាការ ។</u>**